ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 004/2/07-09-2009-ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Aug-2020, 16:00
CMS/CFO: Sann Rada

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រ៊ឹម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen Harding CLARK
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២០

ភាសាដើម៖ ខ្មែរ/អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ:

# សេចក្តីសម្រេច
## លើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលចាត់វិធានការចាំបាច់ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានតំណាងផ្លូវច្បាប់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០៤/២

**សហព្រះរាជអាជ្ញា**
ជា លាង

**ជនជាប់ចោទ**
អោ អាន

Brenda J. HOLLIS

**សហមេធាវីជនជាប់ចោទ**

មុំ លុជ្ស
Richard ROGERS
Goran SLUITER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
សំ សុគង់
ស៊ិន សារ៉ន
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Nushin SARKARATI

ជេត វណ្ណលី
គឹម ម៉េងឃី
ទី ស្រ៊ីនណា
វ៉េន ពៅ
Laure DESFORGES
Isabelle DURAND
Lyma NGUYEN

*សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលចាត់ វិធានការចាំបាច់ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានតំណាងផ្លូវច្បាប់ នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០៤/២*

1. **អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" ឬ"អង្គជំនុំជម្រះ" និង "អ.វ.ត.ក" នីមួយៗ) បានទទួលសំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលចាត់វិធានការចាំបាច់ ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការទទួលបានតំណាងផ្លូវច្បាប់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២[1]។

## I. <u>**ប្រវត្តិនីតិវិធី**</u>

2. នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីប្រាំបីរូបបានដាក់សំណើសុំអង្គបុរេជំនុំជម្រះឱ្យចាត់វិធានការចាំបាច់ក្នុងការការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២[2]។

3. នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងទៅនឹងអ្វីដែលខ្លួនចាត់ទុកថា ជាការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង[3]។

---

[1] សំណើរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលចាត់វិធានការចាំបាច់ ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការទទួលបានតំណាងផ្លូវច្បាប់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០ ឯកសារលេខ E004/2/5 ("សំណើ")។

[2] សំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីសុំវិធានការចាំបាច់ធ្វើឡើងដោយអង្គបុរេជំនុំជម្រះដើម្បីការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០៤/២ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០២០ ឯកសារលេខ D359/33 & D360/42។

[3] បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០ ឯកសារលេខ E004/2/1 ជូនដំណឹងនៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០២០ ("បណ្ដឹងសាទុក្ខភ្លាមៗ")។

4. នៅថ្ងៃដដែល សហព្រះរាជអាជ្ញាអន្តរជាតិបានចម្លងជូនជាការគួរសមនៃបណ្តឹងសាទុក្ខភ្លាមៗតាមរយៈអ៊ីមែលទៅអង្គជំនុំជម្រះតុលាការកំពូល មេធាវីការពារក្តី អោ អាន និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[4] ព្រមទាំងទៅអង្គជំនុំជម្រះសាលាដំបូង និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[5]។

5. នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០២០ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិបានឆ្លើយតបទៅនឹងអ៊ីមែលរបស់សហព្រះរាជអាជ្ញាអន្តរជាតិដោយជូនដំណឹងអង្គជំនុំជម្រះ និងភាគីថា ឋានៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិនៅក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/២ ពុំទាន់មានភាពច្បាស់លាស់ និងពុំអាចចូលមើលសំណុំរឿងនេះបាន និងដឹងថា ការតែងតាំងរបស់ខ្លួនត្រូវបានកម្រិតត្រឹមសំណុំរឿង ០០២ និងបានឱ្យដឹងថា ពុំមានសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីណាមាននៅក្នុងកំណត់ត្រានៃសំណុំរឿង ០០៤/២ ឡើយ។ ដូចនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិបានស្នើសុំថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគប្បី"ត្រូវបានបន្តជូនដំណឹងនូវរាល់ការទំនាក់ទំនងណាមួយ"[6]។

---

[4] អ៊ីមែលរបស់លោកស្រីសហព្រះរាជអាជ្ញាអន្តរជាតិ Brenda HOLLIS ចំណងជើងថា "ចម្លងជូនជាការគួរសមនៃបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង សហមេធាវីការពារក្តី អោ អាន និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី *សូមមើល* ឯកសារលេខ E004/2/5.1.2។

[5] អ៊ីមែលរបស់លោកស្រីសហព្រះរាជអាជ្ញាអន្តរជាតិ Brenda HOLLIS ចំណងជើងថា "ចម្លងជូនជាការគួរសមនៃបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង សហមេធាវីការពារក្តី អោ អាន និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារលេខ E004/2/5.1.1។

[6] អ៊ីមែលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ Megan HIRST ចំណងជើងថា "ឆ្លើយតបៈ ចម្លងជូនជាការគួរសមនូវបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០២០ ផ្ញើជូនសហព្រះរាជអាជ្ញាអន្តរជាតិ អង្គជំនុំជម្រះ សហមេធាវីការពារក្តី អោ អាន និងចម្លងជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារលេខ E004/2/5.1.2។

6. នៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០២០ អោ អាន បានដាក់សារណាតបរបស់ខ្លួន[7]។ នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ការឆ្លើយតប[8]។

7. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០២០ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើសុំនេះ[9]។

8. នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០២០ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួនលើសំណើសុំរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងបានបដិសេធចោលទាំងស្រុង[10]។

9. នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០ អង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខភ្លាមៗ[11]។

## II. <u>**សារណា**</u>

10. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកថា តាមវិធានផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតំណាងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលមុនការជំនុំជម្រះ (ឧ. នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ) និងតំណាងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅដំណាក់កាលជំនុំជម្រះឡើងទៅ (ឧ. នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំ

---

[7] សារណាតបរបស់ អោ អាន ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង បញ្ជូននៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០២០ ជូនដំណឹងនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ ("សារណាតប")។

[8] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងលិខិតរបស់ អោ អាន ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់ខ្លួនប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E004/2/1/1/1 ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០២០ ("ការឆ្លើយតប")។

[9] សំណើ កថាខណ្ឌ ១។

[10] សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំវិធានការចាំបាច់ធ្វើឡើងដោយអង្គបុរេជំនុំជម្រះក្នុងការការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០២០ ឯកសារលេខ D359/39 និង D360/48 ("សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី")។

[11] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២០ E004/2/1/1/2 ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ")។

ជម្រះតុលាការកំពូល)[12]។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា ក្នុងសំណុំរឿង ០០៤/២ ដើមបណ្ដឹងរដ្ឋប្បវេណីពុំមានតំណាងផ្លូវច្បាប់ក្នុងការការពារសិទ្ធិជាមូលដ្ឋានរបស់ខ្លួនក្នុងការបង្ហាញខ្លួន និងការស្ដាប់ពីតុលាការនៅក្នុងបណ្ដឹងសាទុក្ខភ្លាមៗ ពីព្រោះវិធានផ្ទៃក្នុងពុំបានផ្ដល់សិទ្ធិអំណាចដល់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញខ្លួនចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និងរហូតមកដល់បច្ចុប្បន្ន តុលាការពុំបានទទួលស្គាល់អាណត្តិរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ដែរ[13]។ ជាលទ្ធផល ខុសពីមេធាវីការពារក្ដី ដើមបណ្ដឹងរដ្ឋប្បវេណីពុំមានឱកាសត្រូវបានស្ដាប់លើបណ្ដឹងសាទុក្ខ ដោយសារកង្វះភាពច្បាស់លាស់នៃការតំណាងផ្លូវច្បាប់របស់ខ្លួន[14]។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានការស្ដាប់ដោយតុលាការក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/២ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[15] ដែលលើកឡើងអំពីសិទ្ធិច្បាស់លាស់ក្នុងការទទួលបានតំណាងផ្លូវច្បាប់[16]។

11. ផ្អែកលើមូលដ្ឋាននេះ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យទទួលស្គាល់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើជាតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសមស្របក្នុងការដាក់សារណានៅចំពោះមុខអង្គជំនុំជម្រះ និងបង្គាប់ឱ្យការិយាល័យរដ្ឋបាលអនុញ្ញាតឱ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចូលមើលសំណុំរឿង ០០៤/២ ("សំណុំរឿង")។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក៏បានស្នើសុំផងដែរថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីត្រូវទទួលបានការពន្យារពេលសមហេតុផលដប់ថ្ងៃក្នុងការដាក់សារណារបស់ខ្លួន។ ជាជម្រើស មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា ខ្លួនមានអត្ថិភាពក្នុងការ

---

[12] សំណើ កថាខណ្ឌ ៣ ១៣ ១៥។

[13] សំណើ កថាខណ្ឌ ២១ ២៣។

[14] សំណើ កថាខណ្ឌ ២២ ដល់ ២៣។

[15] សំណើ កថាខណ្ឌ ២៤ ដល់ ២៨។

[16] សំណើ កថាខណ្ឌ ២៤ ២៩ ដល់ ៣២។

ដាក់សារណាចំពោះមុខអង្គជំនុំជម្រះ និងអនុញ្ញាតឱ្យដាក់សារណាដែលជាឧបសម្ព័ន្ធភ្ជាប់មកជាមួយនោះផង[17]។

12. ពុំមានការឆ្លើយតបពីភាគីលើសំណើសុំនេះ។

## III. ច្បាប់ជាធរមាន

13. វិធាន ៣៩ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធទៅនឹង'កាលបរិច្ឆេទ និងលក្ខខណ្ឌសម្រាប់ការដាក់ឯកសារ ចែងថា៖

> ១. រាល់កាលបរិច្ឆេទដែលត្រូវបានកំណត់ក្នុងច្បាប់ជាធរមាន និងវិធានផ្ទៃក្នុងនេះ សេចក្ដីណែនាំអនុវត្តជាធរមាន និងក្នុងករណីសមស្រប តាមរយៈសេចក្ដីសម្រេចរបស់ចៅក្រម ត្រូវគោរពតាម។ អនុលោមតាមវិធាននេះ ការខកខានក្នុងការធ្វើដូច្នោះ ត្រូវនាំទៅរកការអស់សុពលភាពនៃកិច្ចដែលកំពុងបំពេញនោះ [...]
>
> [...]
>
> ៤. [...] តាមសំណើរបស់ភាគីពាក់ព័ន្ធ ឬគំនិតផ្តួចផ្តើមរបស់ខ្លួន អង្គជំនុំជម្រះអាច៖
>
> a) ពន្យារកាលបរិច្ឆេទដែលបានកំណត់ដោយវិធានខាងលើ ឬ
>
> b) ទទួលស្គាល់សុពលភាពនៃកិច្ចណាមួយដែលបានអនុវត្តក្រោយពេលកាលបរិច្ឆេទផុតកំណត់ដែលមានចែងក្នុងវិធានទាំងនេះស្តីពីលក្ខខណ្ឌបែបនេះ ក្នុងករណីដែលខ្លួនយល់ឃើញថាត្រឹមត្រូវ។

## IV. ការពិភាក្សា

### *1. ភាពអាចទទួលយកបាននៃសំណើ*

14. អង្គជំនុំជម្រះសង្កេតឃើញថា មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សំណើមានខ្លឹមសារប្រហាក់ប្រហែលគ្នានឹងសំណើដែលបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះកាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ សុំឱ្យចាត់វិធានការក្នុងការការពារសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២។ ជាពិសេស សុំឱ្យខ្លួនទទួលបានការជូនដំណឹងរាល់ការដាក់ឯកសារ និងការទំនាក់ទំនងកន្លងមក និងពេលអនាគតពាក់ព័ន្ធទៅនឹងសំណុំរឿង ០០៤/២ និងសុំឱ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

[17] សំណើ កថាខណ្ឌ ៤០។ *សូមមើលផងដែរ* កថាខណ្ឌ ២៤ ៣៣ ដល់ ៣៧ ៣៩។

អាចចូលមើលសំណុំរឿង ០០៤/២[18]។ គួរកត់សម្គាល់ថា សេចក្តីសម្រេចអង្គបុរេជំនុំជម្រះពុំទាន់បានបញ្ចប់នៅខណៈពេលដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដាក់សំណើរបស់ខ្លួននេះ[19]។ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះត្រូវបានចេញនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០២០ ដោយបានបដិសេធសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុង[20]។ អង្គបុរេជំនុំជម្រះក៏បានសម្រេចផងដែរថា សំណើសុំបង្គាប់ថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឱ្យចូលមើលសំណុំរឿង“ពុំអាចត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះនៅដំណាក់កាលនេះឡើយ”[21]។

15. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ពីការលំបាកយ៉ាងខ្លាំង និងស្ថានការណ៍ធ្វើឱ្យភាន់ច្រឡំផ្នែកច្បាប់ដែលបានបង្កើតឡើងដោយភាពផ្ទុយគ្នានៃ *សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ*លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយដោយបានប្រកាសជាឯកច្ឆន្ទថា “ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ រំលោភបំពានលើក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក.” និងបន្ទាប់មក ការប្រកាសផ្សេងៗគ្នានូវសុពលភាពនៃដីកាតែមួយដែលរងការជំទាស់នោះ[22]។ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយលើគោលជំហរដែលពុំធ្លាប់មានពីមុនមកនេះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខភ្លាមៗ[23]។

16. ទាក់ទងទៅនឹងការកំណត់ពេលវេលា និងការដាក់ឯកសារយឺតពេល មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា៖

---

[18] សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំចាត់វិធានការចាំបាច់ធ្វើឡើងដោយអង្គបុរេជំនុំជម្រះដើម្បីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ឯកសារលេខ D359/33 និង D360/42។

[19] សំណើ កថាខណ្ឌ ៥។

[20] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[21] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤(ខ) ១៧។

[22] អង្គបុរេជំនុំជម្រះ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ* ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ ឯកសារលេខ D359/24 & D360/33 វគ្គ VII។ ផ្នែកសម្រេចសេចក្តី (ERN 01634239) និងមតិជំទាស់របស់ចៅក្រមជាតិ (ERN 01634241-01634276) និងអន្តរជាតិ (ERN 01634277-01634444) (“សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ”)។

[23] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៦៧ ដល់ ៧១។

"បរិយាកាសទូទៅនៃអនិយតភាពនីតិវិធី ការទំនាក់ទំនងពុំអាចទុកចិត្តបាន និងការធ្វើឱ្យភាន់ច្រឡំ [...] បានបន្តជាអត្ថិភាពក្នុងសំណុំរឿង ០០៤/២ និងក្នុងកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នចំពោះមុខអង្គជំនុំជម្រះ។ ជាផលវិបាក អត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការត្រូវបានស្តាប់ និងសិទ្ធិទទួលបានការចូលរួមត្រឹមត្រូវស្មើភាពគ្នាជាភាគីចំពោះកិច្ចដំណើរការនីតិវិធី ត្រូវបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ រួមទាំងលទ្ធភាពរបស់ខ្លួនក្នុងការទទួលបានការជូនដំណឹង និងឆ្លើយតបទៅនឹងការដាក់ឯកសារដោយភាគីដទៃ និងអង្គជំនុំជម្រះនានានៃតុលាការ។ ផ្អែកតាមការពិចារណាលើកាលៈទេសៈទាំងនេះ វាផ្តល់អត្ថប្រយោជន៍យុត្តិធម៌ដែលថា បើទោះបីជាមានការកំណត់កាលបរិច្ឆេទណាមួយ[ដែលអង្គជំនុំជម្រះ]យល់ឃើញថា អាចអនុវត្តបានចំពោះសារណាដែលបានស្នើឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ ក៏អង្គជំនុំជម្រះត្រូវផ្អែកលើយុត្តាធិការឆន្ទានុសិទ្ធិ និង/ឬ វិធាន ៣៣ នៃវិធានផ្ទៃក្នុង ផ្តល់ការអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់ឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ"[24]។

17. អង្គជំនុំជម្រះកត់សម្គាល់លើភាពយឺតយ៉ាវនៃការដាក់សំណើនេះ។ ទោះជាយ៉ាងណាក្តី អនុលោមតាមវិធាន ៣៩(៤)(ខ) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះទទួលយកហេតុផលដែលបានផ្តល់ដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះនឹងត្រូវប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីកំណត់លើសំណើនេះសម្រាប់គោលបំណងដើម្បីផ្តល់ការបំភ្លឺផ្នែកច្បាប់លើបញ្ហានៃការតំណាងផ្លូវច្បាប់។ សំណងដែលស្នើសុំពីអង្គជំនុំជម្រះតុលាការកំពូលក្នុងការអនុញ្ញាតឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចូលមើលសំណុំរឿង ក៏ត្រូវបានស្នើសុំផងដែរនៅចំពោះមុខអង្គបុរេជំនុំជម្រះ និងត្រូវបានបដិសេធចោល[25]។ សេចក្តីសម្រេចនោះបិទផ្លូវតវ៉ា។

18. មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកថា ជាការចាំបាច់ក្នុងការការពារគោលជំហរដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះទទួលយកសំណើយឺតពេលនេះសម្រាប់ហេតុផលដែលបានលើកឡើងខាងលើ។

---

[24] សំណើ កថាខណ្ឌ ៣៨។

[25] សេចក្តីសម្រេចអង្គបុរេជំនុំជម្រះលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៤(ខ) និង ១៧។ *សេចក្តីសម្រេចលើសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំអង្គជំនុំជម្រះតុលាការកំពូលចាត់ ៩/១២ វិធានការចាំបាច់ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានតំណាងផ្លូវច្បាប់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០៤/២*

## ២. អង្គសេចក្ដីនៃសំណើ

19. ទាក់ទងទៅនឹងកាលៈទេសៈពិសេសនៃសំណើចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលមាន៖ សំណើពីរដែលបានស្នើសុំដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ សំណើទីមួយ គឺសុំឱ្យទទួលយកការបំភ្លឺលើបញ្ហាថាតើ នរណាគឺជាតំណាងសមស្របរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងកាលៈទេសៈបច្ចុប្បន្ន ដោយសារពុំមានភាពច្បាស់លាស់ថា តើតំណាងមួយណារបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជាអ្នកស្នើសុំមកអង្គជំនុំជម្រះ។ សំអាងហេតុរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គឺថា តំណាងផ្លូវច្បាប់សម្រាប់ជនរងគ្រោះ មានលក្ខណៈខុសៗគ្នា អនុលោមតាមវិធានផ្ទៃក្នុងនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី[26]។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី គប្បីត្រូវបានទទួលស្គាល់ជាតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសមស្រប ក្នុងការដាក់សារណាចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល និងគប្បីត្រូវអនុញ្ញាតចូលមើលសំណុំរឿង[27]។ ជាជម្រើស មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឱ្យទទួលស្គាល់ និងមានអត្ថិភាពក្នុងការដាក់សារណាចំពោះមុខអង្គជំនុំជម្រះ[28]។ សំណើទីពីរ គឺថា តំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ គប្បីត្រូវបានអនុញ្ញាតដាក់សារណារបស់ខ្លួន បើទោះបីជាមានសារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវដាក់នូវសេចក្ដីបំភ្លឺក្នុងរយៈពេល ១០ ថ្ងៃ[29] ឬជាសារណារបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសំណើនេះក៏ដោយចុះ[30]។

20. តាមមតិនៃការប្រកាសជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះបានឱ្យដឹងថា "ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺខុសច្បាប់ រំលោភបំពានលើក្របខ័ណ្ឌគតិយុត្តិរបស់ អ.វ.ត.ក."[31] អង្គជំនុំជម្រះតុលា

[26] សំណើ កថាខណ្ឌ ២១ ២៣ ២៤(ខ) ២៩ ដល់ ៣២(ក) និង (ឃ)។

[27] សំណើ កថាខណ្ឌ ៣៣ ដល់ ៣៨(ក)។

[28] សំណើ កថាខណ្ឌ ៤០(ឃ)។

[29] សំណើ កថាខណ្ឌ ៤០(គ)។

[30] សំណើ កថាខណ្ឌ ៤០(ង)។ ឧបសម្ព័ន្ធ ក៖ សំណើដាក់ឯកសារ: សារណារបស់ដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីឋានៈនៃសំណុំរឿង ០០៤/២ និងសិទ្ធិរបស់ជនរងគ្រោះក្នុងកិច្ចដំណើរការនីតិវិធីនេះ ឯកសារលេខ E004/2/5.2។

[31] សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ វគ្គ VII។ ផ្នែកសម្រេចសេចក្ដី ERN 01634239។

ការកំពូលកំណត់នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខភ្លាមៗក្នុងសំអាងហេតុថា "អង្គជំនុំជម្រះសង្កេតឃើញថា ពុំមានដីកាដំណោះស្រាយណាមួយមានសុពលភាព" និងថា "ដោយសារពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះជាក់លាក់ និងអាចអនុវត្តបាន ហេតុនេះ រឿងក្តី អោ អាន ត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក."[32]។

21. សេចក្តីបញ្ជាក់ទូទៅនៃការយល់ឃើញទាំងនោះ មានន័យថា សំណុំរឿង ០០៤/២ បានមកដល់ទីបញ្ចប់ នៅពេលដែលអង្គបុរេជំនុំជម្រះចេញសេចក្តីពិចារណារបស់ខ្លួននៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩។ ដោយហេតុថា វាគួរតែមានលទ្ធផលល្អប្រសើរជាងនេះប្រសិនណាបើសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះមានតម្លាភាព និងច្បាស់លាស់ជាងនេះ ដូច្នេះជៀសពុំរួចពីការពិតដែលថា ពុំមានដីកាដំណោះស្រាយសុពលភាពចាំបាច់មួយត្រូវបានសម្របសម្រួលដោយទទួលបានការយល់ឃើញ និងការប្រកាសជាឯកច្ឆន្ទពីអង្គបុរេជំនុំជម្រះនោះឡើយ។ សំណុំរឿងនេះពុំគប្បីត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង ហើយពុំមានអត្ថិភាពនៅចំពោះអង្គជំនុំជម្រះតុលាការកំពូលដែរ។ អាស្រ័យហេតុនេះ លែងតម្រូវឱ្យមានភាពចាំបាច់តទៅទៀតសម្រាប់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចូលមើលសំណុំរឿងនេះឡើយ ។ ដោយហេតុថា សំណុំរឿងនេះពុំដែលត្រូវបានបញ្ជូនពីអង្គបុរេជំនុំជម្រះ ទើបតួនាទីជាតំណាងរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤/២ ត្រូវបញ្ចប់អានុភាព។ តួនាទីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពុំត្រូវបានយកមកប្រើប្រាស់ ដោយសារអង្គជំនុំជម្រះសាលាដំបូងពុំដែលបានទទួលសំណុំរឿង ០០៤/២។

22. ផ្នែកផ្សេងទៀតនៃសំណុំសុំបំភ្លឺ ថាតើ នរណាជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសម្រេចដោយសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ និងពុំចាំបាច់ត្រូវដោះស្រាយឡើយ។ វិធានផ្ទៃក្នុងបានចែងច្បាស់លាស់ និងគ្រប់គ្រាន់សម្រាប់ពេលណាដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើសកម្មភាពក្នុងការតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ទោះជាយ៉ាងណាក្តី ពុំមានតំណាងណាមួយត្រូវបានកោះហៅនៅពេលដែលរឿងក្តីមួយ ត្រូវបានបញ្ចប់ដោយអានុភាពនៃសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះឡើយ។

---

[32] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ កថាខណ្ឌ ៧១ ចំណុច v និង vi។

23. អង្គជំនុំជម្រះតុលាការកំពូលទទួលស្គាល់ថា នេះជាកាតព្វកិច្ចរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការការពារអត្ថប្រយោជន៍ជនរងគ្រោះ និងទាញចំណាប់អារម្មណ៍របស់អង្គជំនុំជម្រះទៅលើការរំលោភបំពានណាមួយ ឬការធ្វើឱ្យប៉ះពាល់ដល់សិទ្ធិត្រឹមត្រូវតាមច្បាប់ទាំងនោះ។ អង្គជំនុំជម្រះពុំធ្វើការទិតៀនណាមួយលើក្រុមមេធាវីទាំងពីរតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសកម្មភាពដែលខ្លួនត្រូវបំពេញនោះឡើយ។

## V. **ផ្នែកសម្រេចសេចក្តី**

24. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូលសម្រេច៖

**សំណើសុំ**អាចទទួលយកបានតាមទម្រង់

**បដិសេធ**សំណើសុំនេះ។

**រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០២០**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**